ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

លេខ០៦២ សសរ /គ.ជ.ប.ទ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០០៨

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមគោលនយោបាយ
# នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន
## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការរៀបចំការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញប្រកាសលេខ០៩៥ ប្រ.ក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត "**ក្រុមគោលនយោបាយ**" ជាភាសាអង់គ្លេសហៅថា "Policy Team" ក្រោម

វចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.វ.វ សម្រាប់សិក្សារៀបចំតាក់តែងសេចក្ដីព្រាងរាល់លិខិតបទដ្ឋានច្បាប់ ពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**ប្រការ ២.-**

ក្រុមគោលនយោបាយត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូប ។

ក្រុមគោលនយោបាយត្រូវចែកចេញជាបីផ្នែកគឺ ១).ផ្នែកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនង "Cooperation and Liaison Unit" ២).ផ្នែកក្របខ័ណ្ឌច្បាប់ "Legal Framework Unit" ៣).ផ្នែកកសាងសមត្ថភាព និងព័ត៌មាន "Capacity Development and Information Unit" ។

**ប្រការ ៣.-**

ក្រុមគោលនយោបាយត្រូវមានសមាសភាពដឹកនាំដូចខាងក្រោម :

១- លោក **អ៊ែច ប៊ុនថុល** ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ជាប្រធានក្រុមគោលនយោបាយ និងជាប្រធានផ្នែកក្របខ័ណ្ឌច្បាប់

២- លោក **សូ មុន្នីរក្សា** អនុប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ ជាអនុប្រធានក្រុមគោលនយោបាយ និងជាប្រធានផ្នែកកសាងសមត្ថភាពនិងព័ត៌មាន

៣- លោក **ឆេង ណៃ** ប្រធានលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាអនុប្រធានក្រុមគោលនយោបាយ និងជាប្រធានផ្នែកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនង

៤- លោក **សរ គីរីរ៉ា** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ ជាអនុប្រធានផ្នែកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនង

៥- លោក **អ៊ួច ចន្នី** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាអនុប្រធានផ្នែកក្របខ័ណ្ឌច្បាប់

៦- លោក **សុខ ចំរើន** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាអនុប្រធានផ្នែកកសាងសមត្ថភាពនិងព័ត៌មាន

**ប្រការ ៤.-**

ដើម្បីអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព លេខាធិការដ្ឋាន គ.ជ.វ.វ ត្រូវធ្វើការជ្រើសរើសមន្ត្រីជំនាញពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីបំពេញឱ្យផ្នែកនីមួយៗនៃក្រុមគោលនយោបាយតាមការចាំបាច់ ។

**ប្រការ ៥.-**

ក្នុងការអនុវត្តការងាររបស់ខ្លួន ក្រុមគោលនយោបាយត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវជាមួយ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋានគ.ជ.វ.វ ។

**ប្រការ ៦.-**

ក្រុមគាំទ្រកម្មវិធីមានភារកិច្ចទទួលខុសត្រូវ និងគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែករដ្ឋបាលទូទៅដល់ក្រុមគោលនយោបាយ ។

**ប្រការ ៧.-**

ក្រុមគោលនយោបាយមានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- អនុវត្តការងារប្រចាំថ្ងៃ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំនានា ដែលសម្រេចដោយ គ.ជ.វ.វ និងត្រូវទទួលខុសត្រូវផ្ទាល់ចំពោះមុខ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋាន គ.ជ.វ.វ
- ជាសេនាធិការឱ្យ គ.ជ.វ.វ ក្នុងការសម្របសម្រួលរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ
- រៀបចំទុកដាក់ឯកសារ សេចក្តីសម្រេច និង/ឬ លិខិតបទដ្ឋាននានារបស់ គ.ជ.វ.វ ព្រមទាំងជំរុញ និងតាមដានការអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.វ.វ
- ទទួលការណែនាំ និងតម្រង់ទិសពីក្រុមរៀបចំតាក់តែងកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម និងជាជំនួយការឱ្យក្រុមរៀបចំតាក់តែងកម្មវិធីជាតិនេះ
- រៀបចំតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋាននានា ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ពិនិត្យ និងធ្វើការកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានអនុវត្តនានាដែលបានរៀបចំឡើងក្រោមច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យស្របតាមគោលការណ៍ដែលមានចែងក្នុង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំផែនការបណ្តុះបណ្តាល និងធ្វើការកសាងសមត្ថភាពដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យសមស្របតាម ដើម្បីធានាការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- សហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា និងក្រុមគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.វ.វ ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពនានារបស់ គ.ជ.វ.វ
- ក្នុងការអនុវត្តការងាប្រចាំថ្ងៃ ក្រុមគោលនយោបាយត្រូវធ្វើការសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា និងក្រុមគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.វ.វ ក្នុងករណីមានការចាំបាច់
- ពិនិត្យ តាមដាន វាយតម្លៃ ការអនុវត្តលក្ខខណ្ឌការងារនៃបុគ្គលិករបស់ខ្លួន ដែលមានចែងក្នុងកិច្ចសន្យាការងារ
- រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិការបស់ខ្លួន
- ធ្វើរបាយការជាប្រចាំ និងតាមការកំណត់របស់ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋាន គ.ជ.វ.វ។

**ប្រការ ៨.-**

ក្រសួង ស្ថាប័នជាសមាជិក គ.ជ.វ.វ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងឯកឧត្តម អស់លោកដែលមានឈ្មោះនៅក្នុងប្រការ៣ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៩.-**

បទប្បញ្ញត្តិរបស់ គ.ជ.វ.វ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រធាន គ.ជ.វ.វ**

ស ខេង

**កន្លែងទទួល :**

- ក្រសួងសមាជិក គ.ជ.វ.វ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មការប្រតិបត្តិគ្រប់ខេត្ត ក្រុង
- ដៃគូអភិវឌ្ឍន៍ UNDP DFID SIDA (ដើម្បីជូនជ្រាប)
- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ